**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកែសម្រួលមហាវិទ្យាល័យបញ្ជាការសេនាធិការ ទៅជាវិទ្យាស្ថានបញ្ជាការសេនាធិការ ចំណុះអគ្គបញ្ជាការដ្ឋាន

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខនស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០១/២៣៧ ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០១ ស្ដីពីការកែសម្រួលតួនាទីភារកិច្ច និងរចនាសម្ពន្ធចាត់តាំង របស់អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ៣៣ អនក្រ.បក ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២៤ ស្ដីពីការផ្ទេរមហាវិទ្យាល័យបញ្ជាការសេនាធិការរបស់សាកលវិទ្យាល័យការពារជាតិ ពីចំណុះក្រសួងការពារជាតិ ទៅដាក់ចំណុះអគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការពារជាតិ

## សម្រេច

**មាត្រា១.-**

ត្រូវបានកែសម្រួលមហាវិទ្យាល័យបញ្ជាការសេនាធិការ ទៅជាវិទ្យាស្ថានបញ្ជាការសេនាធិការ ចំណុះអគ្គបញ្ជាការដ្ឋាន សរសេរអក្សរកាត់ **វ.ប.ស**។

**មាត្រា២.-**

វិទ្យាស្ថានបញ្ជាការសេនាធិការ មានតួនាទីធ្វើការងារបណ្ដុះបណ្ដាល និងបំប៉ននាយទាហានសេនាធិការ នៃកងយោធពលខេមរភូមិន្ទ និងមានភារកិច្ចដូចខាងក្រោម៖

- សិក្សាស្រាវជ្រាវ ចងក្រងឯកសារជំនាញពាក់ព័ន្ធនឹងការហ្វឹកហ្វឺន បណ្ដុះបណ្ដាលនាយទាហានស្របតាមតួនាទីភារកិច្ច ការងារសេនាធិការ នៃកងយោធពលខេមរភូមិន្ទ។
- កសាង និងពង្រឹងហេដ្ឋារចនាសម្ពន្ធ និងសម្ភារៈគ្រឿងបំពាក់ បម្រើការងារគ្រប់វិស័យរបស់វិទ្យាស្ថាន។

- សហការជាមួយក្រសួង ស្ថាប័ន និងកងឯកភាពពាក់ព័ន្ធ ក្នុងការរៀបចំសាស្ត្រាចារ្យ យោធាចារ្យ សម្រាប់មុខវិជ្ជាជំនាញ នៃវគ្គបណ្តុះបណ្តាល និងវគ្គបំប៉ន តាមសេចក្តីត្រូវការចាំបាច់ នៃកម្មវិធីសិក្សារបស់វិទ្យាស្ថាន។
- អនុវត្តភារកិច្ចផ្សេងៗទៀត ដែលថ្នាក់លើប្រគល់ឱ្យ។

**មាត្រា៣.-**

វិទ្យាស្ថានបញ្ជាការសេនាធិការ អគ្គបញ្ជាការដ្ឋានដឹកនាំដោយនាយក ០១ (មួយ)រូប និងអមដោយនាយករងមួយចំនួនជាជំនួយការ តាមការចាំបាច់។

តួនាទី ភារកិច្ច រចនាសម្ពន្ធ និងក្របខ័ណ្ឌចាត់តាំងលម្អិត របស់វិទ្យាស្ថានបញ្ជាការសេនាធិការ អាស្រ័យដោយក្រសួងការពារជាតិកំណត់។

**មាត្រា៤.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៥.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អគ្គមេបញ្ជាការនៃកងយោធពលខេមរភូមិន្ទ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ ៣រោច ខែ ជេស្ឋ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មិថុនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

**នាយឧត្តមសេនីយ៍ ទៀ សីហា**

**កន្លែងទទួល**

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យ ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី
-ដូចមាត្រា៥
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ